ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១០៧/១៩ - លីដា នីតធីង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ គល់ វឌ្ឍនា
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អាន វីរៈ
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ សុខ ម៉ាធឿង

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៨៤ ១៩ ៣៦ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖ អវត្តមាន

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៩៦ ៧៧៧ ២១ ៥៨ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ផាត រស្មី | តំណាងកម្មករ |
| ២- លោកស្រី ខាន់ ស្រៀង | កម្មករផ្នែកដេរ |
| ៣- លោកស្រី យក់ ហ៊ុច | កម្មករផ្នែក... |
| ៤- លោកស្រី ទូច គីមអ៊ី | កម្មករផ្នែកឆែក |
| ៥- លោក ឡុង សុផារិន | កម្មករផ្នែកអ៊ុត |
| ៦- លោក ផ្លុង ហ៊ីម | កម្មករផ្នែកអ៊ុត |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

៧- លោកស្រី វណ្ណៈ សារ៉េន កម្មករផ្នែកអ៊ុត

៨- លោកស្រី សុខ ហុង កម្មករផ្នែកឃ្លាំង

៩- លោក ហង្ស ចន្ទ័ មន្ត្រីសហព័ន្ធសហជីពរក្សាសិទ្ធិកម្មករកម្ពុជា

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ភាគីកម្មករនិយោជិតទាមទារឱ្យលោកនាយកក្រុមហ៊ុនបើកប្រាក់ឈ្នួលខែតុលា ឆ្នាំ២០១៩ ឱ្យបានគ្រប់ចំនួន។ ភាគីក្រុមហ៊ុនបានសន្យាថាបើកប្រាក់ឈ្នួលខែតុលា ឆ្នាំ២០១៩ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោយពិធីបុណ្យអុំទូករួច។ លុះដល់ថ្ងៃកំណត់ ខាងក្រុមហ៊ុនថា មិនមានប្រាក់បើកឡើយ ហើយ ស្នើសុំបើកនៅថ្ងៃទី២០ ខែតុលា វិញ ដោយមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយតំណាងកម្មករនិយោជិត។ មកដល់ថ្ងៃកំណត់ គឺថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩ ក្រុមហ៊ុននៅតែមិនមានប្រាក់បើកឱ្យកម្មករនិយោជិតទាំង ២៥៨នាក់ ឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន លីដា នីតជីង (ខេមបូឌា) លេខ ៩៣៨/១៩ កប/កណ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃអង្គារ ៧កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន លីដា នីតជីង (ខេមបូឌា) ស្តីពីការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនដោះស្រាយលក្ខខណ្ឌការងារចំនួន ១ ចំណុច។ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដដែល មន្ត្រី

ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានធ្វើការផ្សះផ្សាចំណុចវិវាទនេះ ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ចំណុចមិនសះជាចំនួន ១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន លីដា នីតជីង (ខេមបូឌា) លេខ ៩៣៨/១៩ ក.ប/កណ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ១ ចំណុចនេះ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក តាមរយៈលិខិតអញ្ជើញលេខ ៦១៦ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ទៅភាគីនិយោជក និងលិខិតអញ្ជើញលេខ ៦១៧ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ទៅភាគីកម្មករនិយោជិត។ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ដដែល មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានទាក់ទងតាមទូរស័ព្ទ និងតេឡេក្រាម បន្ថែមទៀត ទៅកាន់ភាគីនិយោជកតំណាងដោយលោក ស៊ិន ចាន់ និងភាគីកម្មករនិយោជិត ដើម្បីឱ្យមកចូលរួមក្នុងសវនាការអាជ្ញាកណ្តាល ដោយមានភ្ជាប់ជាមួយនូវព័ត៌មានច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរស័ព្ទ/ទូរសារ សម្រាប់ទំនាក់ទំនងមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយភាគីកម្មករនិយោជិត និងភាគីនិយោជក បានទទួលដឹងព័ត៌មានអំពីថ្ងៃសវនាការនេះផងដែរ។ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩ មុនម៉ោងកំណត់សវនាការ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទូរស័ព្ទទៅតំណាងភាគីនិយោជកចំនួន ០២ លើក គឺនៅម៉ោង ៨ និង ០០ នាទីព្រឹក និងម៉ោង ៨ និង៣០ នាទីព្រឹក ដើម្បីបញ្ជាក់អំពីការចូលរួមសវនាការ ប៉ុន្តែ តំណាងភាគីនិយោជកមិនទទួលទូរស័ព្ទនោះទេ។ ភាគីកម្មករនិយោជិតមានវត្តមាននៅក្នុងសវនាការ។ ដោយឡែក ភាគីនិយោជកអវត្តមានដោយគ្មានហេតុផល។

សេចក្តីបង្គាប់អាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ គឺជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- កំណត់ហេតុស្តីពីការសម្របសម្រួលវិវាទការងារ ករណីក្រុមហ៊ុនមិនបើកប្រាក់ឈ្នួលប្រចាំខែតុលា ឆ្នាំ២០១៩ ជូនបងប្អូនកម្មករនិយោជិតចំនួន ២៥៨នាក់ បម្រើការងារនៅក្រុមហ៊ុន លីដា នីតជីង (ខេមបូឌា) ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

២- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា) លេខ ០២៨/១៩ ក.ប/កណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

៣- កំណត់ហេតុស្តីពីការបើកប្រាក់ឈ្នួលប្រចាំខែតុលា ឆ្នាំ២០១៩ ជូនបងប្អូនកម្មករនិយោជិតចំនួន ២៥៨ នាក់ បម្រើការងារនៅក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា) ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៩។

៤- តារាងប្រាក់ឈ្នួល កម្មករនិយោជិតបម្រើការងារនៅក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា) ត្រូវទទួលបានក្នុងខែតុលា។

៥- ឯកសារជាភាសាបរទេស។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា) លេខ ៩៣៨/១៩ ក.ប/កណ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា) ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា) លេខ ០២៧/១៩ ក.ប/កណ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតលេខ ៦០៦ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក លោកនាយកក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា) ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសមាគមនិយោជក ក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា) ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៦១៦ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៦១៧ កប/អក/វក/លកអ. ចុះថ្ងៃ ពុធ ១កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា) មានសកម្មភាពចម្បងផ្នែកកាត់ដេរ និងចាក់សម្លៀកបំពាក់។ ក្រុមហ៊ុននេះមានដួលកម្មករនិយោជិតសរុបចំនួន ២៥៨ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន លីដា នីតធីង (ខេមបូឌា))*។
- យោងតាមកំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម នៃក្រុមហ៊ុន លីដា នីតធីង(ខេមបូឌា) ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ កម្មករនិយោជិតដែលពាក់ព័ន្ធនៅក្នុងចំណុចវិវាទមានចំនួន ២៥៨ នាក់។ ដោយឡែកនៅក្នុងពាក្យបណ្តឹងរបស់កម្មករនិយោជិត ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ មានឈ្មោះ និងស្នាមមេដៃរបស់កម្មករនិយោជិតដែលជាដើមបណ្តឹងចំនួន ៩២ នាក់ប៉ុណ្ណោះ។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ឈ្នួលខែតុលា ឆ្នាំ២០១៩ ឱ្យបានគ្រប់ចំនួន**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកបើកប្រាក់ឈ្នួលប្រចាំខែតុលា ឆ្នាំ២០១៩ ជូនកម្មករនិយោជិតទាំងអស់។
- ភាគីកម្មករនិយោជិតបានលើកឡើងថា៖
    - ជាការគោលការណ៍នៅក្រុមហ៊ុន និយោជកបើកប្រាក់ឈ្នួលមួយខែម្តង ជូនកម្មករនិយោជិត ថ្ងៃទី១០ នៃខែនីមួយៗ ប៉ុន្តែ ការអនុវត្តជាក់ស្តែង និយោជកមិនបានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត នៅថ្ងៃទី១០ នៃខែនីមួយៗនោះទេ គឺនិយោជកពន្យារការបើកប្រាក់ឈ្នួលទៅថ្ងៃទី១១, ឬទី១២, ឬទី១៣ នៃខែនីមួយៗ។
    - កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុនមិនទាន់បានទទួលប្រាក់ឈ្នួលប្រចាំខែតុលា នៅឡើយទេ។ និយោជកបានសុំពន្យារពេលបើកប្រាក់ឈ្នួលជាច្រើនលើក ដូចជា សុំពន្យារទៅថ្ងៃទី១៥ ខែវិច្ឆិកា ក្រោយមកសុំពន្យារទៅថ្ងៃទី២០ ខែវិច្ឆិកា, និងក្រោយមកទៀតសុំពន្យារទៅថ្ងៃទី២៥ ខែវិច្ឆិកា វិញ។
    - ចាប់ពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ មកនិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើនោះទេ។ ភាគីកម្មករនិយោជិតទទួលដំណឹងថា ក្រុមហ៊ុនអាចនឹងបិទទ្វារលែងដំណើរការផងដែរ។
    - កម្មករនិយោជិតម្នាក់ៗ អាចទទួលបានប្រាក់ឈ្នួលចំនួនប្រហែល ៣០០ ដុល្លារអាមេរិក ក្នុងមួយខែ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានរបស់ភាគីនិយោជក ដែលជាភាគីចុងចម្លើយ?

ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចែងថា ៖"*ក្នុងករណីភាគីណាមួយ បានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់*"។

យោងតាមខ្លឹមសារនៃប្រការ២១ នៃប្រកាសលេខ ០៩៩ ខាងលើ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា នៅពេលដែលភាគីនិយោជកបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជា

ខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចសម្រេចបន្តដំណើរការរបស់ខ្លួន ដោយធ្វើការបើកសវនាការកំបាំងមុខភាគីនិយោជកដែលអវត្តមាននោះបាន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៣/០៤-គួង ហុង, លេខ ១៤៨/០៧-ប៉ាយ ហឺ, លេខ ៩៩/០៩-យឹង ឡែន, លេខ ១៧៣/១១-ជិន អ៊ឹង, លេខ ១៤២/១២-អប្សរា, លេខ ១០៩/១៣-វិទ្យាស្ថាន ប៊ុណ្ណា កម្ពុជា, លេខ ១៦៣/១៤-ស៊ីន ឆាង ស៊ីង ហ្គាមេន (ខេមបូឌា), លេខ ២៥០/១៥-អិល អិល អេស ព្រីនធីង, លេខ ០២២/១៦-អាត់តាខឹស (ខេមបូឌា) ហ្គាមេន)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើនេះដែរ។

នៅក្នុងសំណុំរឿងនេះ និងផ្អែកលើការពន្យល់នៅផ្នែកនីតិវិធីខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញលិខិតអញ្ជើញ និងជូនដំណឹងយ៉ាងត្រឹមត្រូវដល់ភាគីនិយោជក នូវព័ត៌មានអំពីកាលបរិច្ឆេទនៃសវនាការ, ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរសព្ទ/ទូរសារសម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបានទូរស័ព្ទទាក់ទងទៅតំណាងភាគីនិយោជក ដើម្បីបញ្ជាក់អំពីការចូលរួមសវនាការ នៅថ្ងៃសវនាការផងដែរ ប៉ុន្តែ តំណាងភាគីនិយោជកមិនទទួលទូរស័ព្ទនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកបានទទួលការអញ្ជើញត្រឹមត្រូវហើយ។

ដូចនេះ យោងតាមប្រការ ២១ នៃប្រកាសលេខ ០៩៩ និងការបកស្រាយរបស់អាជ្ញាកណ្តាលក្នុងសេចក្តីបង្គាប់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនិយោជកអវត្តមានដោយគ្មានហេតុផលត្រឹមត្រូវបាន។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ឈ្នួលប្រចាំខែតុលា ឆ្នាំ២០១៩ ជូនកម្មករនិយោជិតទាំងអស់**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបើកប្រាក់ឈ្នួលប្រចាំខែតុលា ឆ្នាំ ២០១៩ ជូនកម្មករនិយោជិតទាំងអស់ដែរ ឬទេ?

មាត្រា ១១៨ នៃច្បាប់ស្តីពីការងារ ចែងថា៖ *"ក្នុងករណីមានការប្តឹងជំទាស់អំពីរឿងប្រាក់ឈ្នួល គឺនិយោជកដែលជាអ្នកត្រូវផ្តល់ភស្តុតាងនៃការសងប្រាក់ឈ្នួលរួច។*

*ភស្តុតាងនេះ អាចជាហត្ថលេខានៃសាមីខ្លួនកម្មករនិយោជិត ឬ សាក្សីពីរនាក់ ប្រសិនបើកម្មករនិយោជិតមិនចេះអក្សរបានចុះសៀវភៅបើកប្រាក់ ដែលនិយោជកមានកាតព្វកិច្ចរក្សាទុក"។*

យោងតាមអង្គហេតុ ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតមិនទាន់បានទទួលប្រាក់ឈ្នួលសម្រាប់ខែតុលានៅឡើយ ដោយនិយោជកបានសុំពន្យារពេលបើកប្រាក់ឈ្នួលជាច្រើនដង ហួតដល់ថ្ងៃទី២៥ ខែវិច្ឆិកា។ ហើយមកដល់ពេលនេះ កម្មករនិយោជិតនៅតែមិនទាន់បានទទួលប្រាក់ឈ្នួលនៅឡើយ។ ភាគីនិយោជកបោះបង់សិទ្ធិនៅក្នុងការឆ្លើយតបដោយអវត្តមាននៅថ្ងៃសវនាការ។

ក្នុងករណីនេះ ភាគីនិយោជកមិនបានផ្តល់ភស្តុតាងដើម្បីគាំទ្រអំណះអំណាងបញ្ជាក់ថាបានផ្តល់ប្រាក់ឈ្នួលប្រចាំខែតុលា ជូនកម្មករនិយោជិតនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលជឿលើការលើកឡើងរបស់ភាគីកម្មករនិយោជិត ទាក់ទងនឹងការមិនបានបើកប្រាក់ឈ្នួលប្រចាំខែតុលា ឆ្នាំ២០១៩។

លើសពីនេះ ប្រការ ៣៤ នៃប្រកាស ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចែងថា ៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចលើ*

THE ARBITRATION COUNCIL

*ភាគីវិវាទផ្តល់នូវសំណងជម្ងឺប្បវេណី ឬសំណងខូចខាត ដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ ៖*

*ក...*

*ខ. បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់*

*...”។*

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ឱ្យនិយោជកបើកប្រាក់ឈ្នួលប្រចាំខែតុលា ឆ្នាំ២០១៩ ជូនកម្មករនិយោជិតទាំងអស់ដែលមិនទាន់បានបើកប្រាក់ឈ្នួល ក្នុងរយៈពេល ៧ថ្ងៃ នៃថ្ងៃធ្វើការ (រាប់ចាប់ពីថ្ងៃចេញសេចក្តីបង្គាប់នេះចូលជាស្ថាពរ)។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ៖**

- បង្គាប់ឱ្យនិយោជកបើកប្រាក់ឈ្នួលប្រចាំខែតុលា ឆ្នាំ២០១៩ ជូនកម្មករនិយោជិតទាំងអស់ ដែលមិនទាន់បានបើកប្រាក់ឈ្នួល ក្នុងរយៈពេល ៧ថ្ងៃ នៃថ្ងៃធ្វើការ (រាប់ចាប់ពីថ្ងៃចេញសេចក្តីបង្គាប់នេះចូលជាស្ថាពរ)។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **គល់ ទន្សោនា**

ហត្ថលេខា ៖ ---------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា ៖---------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **សុខ ម៉ាឡឿន**

ហត្ថលេខា ៖ ---------------------------

ARBITRATION COUNCIL